ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៤៤....អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំប្រាក់បំណាច់មុខងារប្រចាំខែរបស់ ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងតាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា១.-

អនុក្រឹត្យនេះ មានគោលបំណងរៀបចំផ្តល់ប្រាក់បំណាច់មុខងារបន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់ប្រឆាំងអំពើពុករលួយ និងប្រាក់សោធនប្រចាំខែជូនប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

មាត្រា២.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ចំនួនប្រាក់បំណាច់មុខងារបន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់ប្រឆាំងអំពើពុករលួយ និងប្រាក់សោធនប្រចាំខែរបស់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

មាត្រា៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

មាត្រា៤.-

ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាននៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលបានប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

ល.រ.	បរិយាយ	ប្រាក់បំណាច់មុខងារ(រៀល)
១	ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ	៨ ០០០ ០០០
២	អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ	៦ ០០០ ០០០
៣	សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ	៥ ០០០ ០០០
៤	ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ	៦ ០០០ ០០០
៥	អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ	៥ ០០០ ០០០

មាត្រា៥.-

ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលបានប្រាក់បំណាច់មុខងារប្រចាំខែតាមកម្រិត ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

បរិយាយ	កម្រិតប្រាក់បំណាច់មុខងារ(រៀល)					
	កម្រិតទី៦	កម្រិតទី៥	កម្រិតទី៤	កម្រិតទី៣	កម្រិតទី២	កម្រិតទី១
ឧបការី	៩០០ ០០០	៩៣០ ០០០	១ ០១០ ០០០	២ ៨០០ ០០០	៣ ៥០០ ០០០	៥ ០០០ ០០០

www.pheakdeylaw.com

មាត្រា៦ .-

ប្រាក់បំណាច់មុខងារប្រចាំខែរបស់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ តទៅ។

ការកែប្រែប្រាក់បំណាច់មុខងារប្រចាំខែរបស់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយត្រូវកំណត់ដោយអនុក្រឹត្យ។

ការកំណត់លក្ខខណ្ឌសម្រាប់ការដំឡើងកម្រិតប្រាក់បំណាច់មុខងារជូនឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវរៀបចំដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

មាត្រា៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣ កើត ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ទេសរដ្ឋមន្ត្រី
ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

ឱម យ៉ិនទៀង

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ពេជ្រ ប៊ុនធិន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com